# អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍ជនជាតិភាគតិច

អង្គការឃែរអន្តរជាតិផ្តោតជាពិសេសទៅលើការធ្វើការជាមួយស្ត្រី និងកុមារីក្នុងគោលបំណងនាំមកនូវការផ្លាស់ប្តូរប្រកបដោយនិរន្តរភាពដល់សហគមន៍របស់ពួកគេ។ នៅក្នុងប្រទេសកម្ពុជា អង្គការឃែរបានចំណាយពេលជាងមួយទសវត្សរ៍មកហើយដើម្បីធ្វើការជាមួយស្ត្រី និងកុមារីដែលមានប្រភពចេញមកពីសហគមន៍ជនជាតិភាគតិច។ អង្គការឃែរកម្ពុជាក៏ផ្តោតជាពិសេសផងដែរទៅលើការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការសិក្សាថ្មីមួយបានប្រមូលផ្តុំនូវជំនាញការចំពោះការងារទាំងពីរផ្នែកនេះក្នុងទិសដៅពិចារណាអំពីស្ថានភាពជាក់លាក់របស់ស្ត្រីនៅក្នុងសហគមន៍ជនជាតិភាគតិចទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការសិក្សាតាមបែបគុណភាពបានរៀបចំធ្វើឡើងក្នុងខែសីហាឆ្នាំ2015 ដោយធ្វើសម្ភាសន៍ក្រុមស្ត្រីនានានៅក្នុងខេត្តរតនគិរី និងបុគ្គលសំខាន់ៗនៅក្នុងសហគមន៍ជនជាតិភាគតិច។

## របកគំហើញសំខាន់ៗ៖
## ប្រភេទ និងអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលស្ត្រីក្នុងខេត្តរតនគិរីបានជួបប្រទះ

### ការអនុវត្តដែលបង្កគ្រោះថ្នាក់

ការរៀបការនៅវ័យក្មេងនៅក្នុងសហគមន៍ដែលបានចុះទៅដល់ គឺជាការអនុវត្តដែលបង្កគ្រោះថ្នាក់ដែលផ្ទេរបន្តពីមួយជំនាន់ទៅកាន់មួយជំនាន់តាមរយៈប្រពៃណី។ ការរៀបការនៅវ័យក្មេងត្រូវបានរាយការណ៍ថាជារឿងធម្មតាតែក៏មានការប្រែប្រួលដែរ។ អាយុនៃការរៀបការនៅវ័យក្មេងត្រូវបានប៉ាន់ប្រមាណថាបានកើនឡើងពីអាយុ13-14ឆ្នាំកាលពីមុន មកដល់អាយុ15-16ឆ្នាំក្នុងពេលបច្ចុប្បន្ននេះ។

> ការរៀបអាពាហ៍ពិពាហ៍ជាច្រើននៅក្នុងសហគមន៍ជនជាតិភាគតិចត្រូវបានប្រារព្ធធ្វើឡើងដោយពុំមានការចុះបញ្ជីអាពាហ៍ពិពាហ៍នោះទេ ដូច្នេះវាអាចបណ្តាលឱ្យមាននូវលទ្ធភាពតិចតួចក្នុងការទទួលបានការជួយគាំទ្រពីរចនាសម្ព័ន្ធផ្លូវការ។

### អំពើហិង្សាលើដៃគូស្និទ្ធស្នាល

### អំពើហិង្សាលើរាងកាយ

ស្ត្រីនៅក្នុងសហគមន៍គោលដៅបានរាយការណ៍ថា ជាទូទៅពួកគេធ្លាប់បានរងអំពើហិង្សាលើរាងកាយពីសំណាក់ប្តី ឬដៃគូរបស់ពួកគេ។ អំពើហិង្សាដែលមិនបង្កឱ្យមានរបួសស្នាមត្រូវបានចាត់ទុកថាជា"អំពើហិង្សាតូចតាច" រីឯអំពើហិង្សាដែលបង្កឱ្យមានការបាក់ឆ្អឹង ស្នាមជាំ ឬស្នាមរបួសត្រូវបានចាត់ទុកថាជា"អំពើហិង្សាធ្ងន់ធ្ងរ"។ អំពើហិង្សាដែលមិនបង្កឱ្យមានរបួសស្នាមត្រូវបានរាយការណ៍ដោយស្ត្រីថាមានការកើតឡើងញឹកញាប់ខ្លាំងជាងអំពើហិង្សាដែលបង្កឱ្យមានរបួសស្នាម។ អ្នកផ្តល់បទសម្ភាសន៍សំខាន់ៗ ខុសៗពីគ្នាមិនយល់ស្របថា តើអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទនៅក្នុងខេត្តរតនគិរីមានការកើនឡើង ឬថយចុះក្នុងប៉ុន្មានឆ្នាំថ្មីៗនេះដែរ ឬយ៉ាងណានោះទេ។

> ទាំងស្ត្រី ទាំងបុរសបានកំណត់ថាអំពើហិង្សាតូចតាចកើតឡើងញឹកញាប់ និងជាបន្ត។

### អំពើហិង្សាលើសេដ្ឋកិច្ច

ជាទូទៅស្ត្រីនៅក្នុងសហគមន៍ជនជាតិភាគតិចត្រូវបានកំណត់ថាជា "អ្នកគ្រប់គ្រង" លុយនៅក្នុងគ្រួសារ ហើយស្ត្រីបានរាយការណ៍ថាពួកគេបានគ្រប់គ្រងលុយនៅគ្រួសារមែន។ ពួកគេអាចធ្វើការសម្រេចចិត្តប្រចាំថ្ងៃអំពីការចំណាយនៅក្នុងគ្រួសារ។ ទោះជាស្ត្រីជាអ្នកគ្រប់គ្រងលុយ ក៏ដោយក៏ "ការសម្រេចចិត្តធំៗ" អំពីការទិញអ្វីៗជាធម្មតាត្រូវបានធ្វើឡើងដោយបុរសដោយពិគ្រោះយោបល់ជាមួយស្ត្រី។ ក្នុងនាមជាមេគ្រួសារវាគឺជាការទទួលខុសត្រូវរបស់បុរសនៅក្នុងការសម្រេចចិត្ត។

> ស្ត្រីជាអ្នកគ្រប់គ្រងលុយនៅក្នុងគ្រួសារប៉ុន្តែ"ការសម្រេចចិត្តធំៗ" ទាក់ទងនឹងលុយបុរសជាអ្នកសម្រេចចិត្ត។

### អំពើហិង្សាលើផ្លូវចិត្ត ឬអារម្មណ៍

ស្ត្រីបានរាយការណ៍ថាពួកគេទទួលរងអំពើហិង្សាលើផ្លូវចិត្ត ឬអារម្មណ៍ជាអាទិ៍ "ពួកគេត្រូវបានគេស្រែកគំហកដាក់ និងត្រូវបានគេនិយាយអាក្រក់ដាក់ដូចជាថាពួកគេឆ្កួត"។ ប្រភេទមួយទៀតនៃអំពើហិង្សាលើផ្លូវចិត្ត ឬអារម្មណ៍ដែលបានលើកឡើងនោះគឺ ប្តីរបស់ពួកគេមានទំនាក់ទំនងស្នេហាជាមួយស្រីផ្សេង។ ជាទូទៅស្ត្រីបានរាយការណ៍ថាមូលហេតុមួយដែលបង្កឱ្យមានអំពើហិង្សានោះ "គឺនៅពេលដែលប្រពន្ធប្រចណ្ឌប្តីថាមានប្រពន្ធចុង ឬថាមានស្ត្រីផ្សេង"។

> ស្ត្រីបានរាយការណ៍ថា អំពើហិង្សាលើផ្លូវចិត្តគឺជារឿងធម្មតានៅក្នុងសហគមន៍ និងបានកើតឡើង "គ្រប់ពេលវេលា"។

### អំពើហិង្សាលើផ្លូវភេទ (ដៃគូ និងមិនមែនដៃគូ)

ជាទូទៅស្ត្រីនៅក្នុងសហគមន៍បានឆ្លើយតបថាការចាប់រំលោភ "មិនមែនជារឿងដែលកើតឡើងជាធម្មតា" នៅក្នុងសហគមន៍នោះទេ។ វាកើតឡើងតែមិនមែនកើតឡើងជាទូទៅដូច "អំពើហិង្សាក្នុងគ្រួសារ" នោះទេ។ ទោះជាដូច្នេះក៏ដោយ ក៏ស្ត្រីនៅតែអាចរៀបរាប់អំពីអាកប្បកិរិយាដែលពួកគេបានប្រើប្រាស់ដើម្បីការពារខ្លួនពីការចាប់រំលោភ។ ស្ត្រីយល់ថាជាប្រពន្ធគេត្រូវធ្វើតាមការស្នើរសុំរួមភេទដែលស្នើឡើងដោយប្តី។ អាជ្ញាធរថ្នាក់ស្រុក និងថ្នាក់ខេត្ត មានលទ្ធភាពច្រើនក្នុងការរាយការណ៍អំពីករណីរំលោភសេពសន្ថវៈដែលបានកើតឡើង។

> របាយការណ៍ផ្សេងៗទាក់ទងនឹងអំពើហិង្សាលើផ្លូវភេទអាចបណ្តាលឱ្យមានភាពខ្មាស់អៀនដែលគេអាចដឹងតាមរយៈការរាយការណ៍។

## របកគំហើញសំខាន់ៗ៖ ប្រភពនៃការជួយគាំទ្រ




បទដ្ឋានសង្គម និងវប្បធម៌ដែលជារឿយនៅជាប់ឋិតថេរជានិច្ចនោះបានជម្រុញឱ្យមានជំនឿថាអំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាបញ្ហាគ្រួសារ និងថាសមាជិកសហគមន៍មិនគួរចូលធ្វើអន្តរាគមន៍នោះទេ។ ទាំងនេះអាចបណ្តាលឱ្យស្ត្រីបរាជ័យក្នុងការស្វែងរកការជួយគាំទ្រ។

នៅពេលស្ត្រីស្វែងរកការជួយគាំទ្រក្នុងជំហានដំបូងនោះគឺគេទៅរកម្តាយ ឪពុកគេឱ្យធ្វើជាអ្នកសម្របសម្រួលដោយគេរំពឹងថាដំបូន្មានពីអ្នកមានគុណរបស់គេ នឹងធ្វើឱ្យប្តីគេបញ្ឈប់អំពើហិង្សា។

ចាស់ព្រឹទ្ធាចារ្យភូមិ ត្រូវបានកំណត់ថាជារដ្ឋអំណាចកណ្តាលនៅក្នុងយន្តការយុត្តិធម៌តាមបែបប្រពៃណីនៅក្នុងសហគមន៍ជនជាតិភាគតិច។ "វិធីដោះស្រាយតាមប្រពៃណី" ដើម្បីឆ្លើយតបនឹងអំពើហិង្សាក្នុងគ្រួសារ គឺត្រូវរៀបចំបើកកិច្ចប្រជុំមួយដែលដឹកនាំចាស់ព្រឹទ្ធាចារ្យជាមួយជនរងគ្រោះនៃអំពើហិង្សា និងប្តីរបស់ជនរងគ្រោះ។

បន្ទាប់ពីស្វែងរកជំនួយតាមប្រពៃណីរួច ជាទូទៅស្ត្រីដែលអមដំណើរដោយអាជ្ញាធរមូលដ្ឋានទៅជួបនគរបាល។ នគរបាលបានរាយការណ៍ថា ជាធម្មតាស្ត្រីមិនចង់ឱ្យគេចាប់ប្តីរបស់ខ្លួនទេពីព្រោះពួកគេត្រូវចំណាយប្រាក់។

ទាំងប្រព័ន្ធយុត្តិធម៌តាមបែបប្រពៃណី ទាំងអាជ្ញាធរមូលដ្ឋានមានការបណ្តុះបណ្តាលតិចតួចស្តីពីអំពើហិង្សាទាក់ទង នឹងយេនឌ័រ ហើយទំនងជានឹងធ្វើឱ្យស្ត្រីក្លាយជាជនរងគ្រោះសាជាថ្មីដោយសារតែផ្តល់ការឆ្លើយតបមិនបានគ្រប់គ្រាន់ ជាលទ្ធផលបែរជាស្តីបន្ទោសស្ត្រីថាជាអ្នកបង្កអំពើហិង្សាទៅវិញ។ ស្ត្រីដែលមានបទពិសោធន៍ធ្លាប់រងនូវអំពើហិង្សាទាក់ទងនឹងយេនឌ័រមានលទ្ធភាពតិចតួចក្នុងការទទួលបានជម្រកដែលមានសុវត្ថិភាព សេវាប្រឹក្សាយោបល់ ការគាំទ្រផ្នែកច្បាប់ និងសេវាសង្គមផ្សេងៗទៀត។

"អំពើហិង្សាជាច្រើនកើតឡើងលើស្ត្រីនៅក្នុងសហគមន៍ភាគច្រើននៅពេលដែលប្តីពួកគេស្រវឹងស្រាតែមានករណីធ្ងន់ធ្ងរមួយចំនួនតូចប៉ុណ្ណោះ"។

អ្នកចូលរួមក្នុងការពិភាក្សាជាក្រុម។

"វាគឺជាការលំបាកខ្លាំងណាស់សម្រាប់ស្ត្រី។ ស្ត្រីភាគច្រើនចង់លាក់លៀម និងមិនឱ្យអ្នកដទៃដឹងនោះទេព្រោះពួកគេនឹងចំណាយលុយច្រើនប្រសិនបើគេដឹងថាមានអំពើហិង្សា"។

ជនបង្គោលរបស់CCWC

"ប្រជាជនមិនចង់ទៅតុលាការទេពួកគេមិនចង់ចំណាយលុយ ឬជាប់ពន្ធនាគារទេ"។

មេឃុំ

ឯកសារលម្អិតស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍ជនជាតិភាគតិច មាននៅលើគេហទំព័ររបស់អង្គការឃែរកម្ពុជា www.care-cambodia.org/research។

care®

ឯកសារស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍ជនជាតិភាគតិចនេះត្រូវបានផលិតឡើងក្រោមការឧបត្ថម្ភពីមូលនិធិ *Pasty Collins Trust Fund Initiative* ក្នុងគម្រោងឫស្សីទោរទន់របស់អង្គការឃែរ។ អង្គការឃែរសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលអូស្ត្រាលី អង្គការ*UNICEF* មូលនិធិ Patsy Collins Trust Fund Initiative និងម្ចាស់ជំនួយឯកជនជាច្រើនដទៃទៀតដែលបានជួយគាំទ្រដល់អង្គការឃែរក្នុងការធ្វើការជាមួយជនជាតិភាគតិចក្នុងប្រទេសកម្ពុជា។